ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០០៧ សហវ

រាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែកក្កដា ឆ្នាំ២០១៣

# សារាចរណែនាំ

## ស្តីពីនីតិវិធីបច្ចេកទេសនៃការរៀបចំ គម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០១៤

យោងសារាចរណែនាំលេខ ០៩ សរណន ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤។

យោងអនុក្រឹត្យលេខ ៣៦ អនក្រ.ប.ក ចុះថ្ងៃទី០៧ ខែមិនា ឆ្នាំ២០១២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិក្រុង ស្រុក។

យោងអនុក្រឹត្យលេខ ១៧២ អនក្រ.ប.ក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក

យោងប្រកាសលេខ ២៨៥ សហវ.ប្រក.ហម ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការដាក់ឲ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំស្តីពីនីតិវិធីបច្ចេកទេសនៃការរៀបចំគម្រោងថវិកាឆ្នាំ២០១៤ របស់រដ្ឋបាលថ្នាក់ក្រោមជាតិដូចខាងក្រោម ៖

គម្រោងចំណូល ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវបានរៀបចំទៅតាមទម្រង់និងចំណាត់ថ្នាក់នៃមាតិកាថវិកា ដូចបានចែងក្នុងតារាងឧបសម្ព័ន្ធទី១ ( តារាងសរុបចំណូលថវិការបស់ថ្នាក់រដ្ឋបាលនីមួយៗ ) តារាងឧបសម្ព័ន្ធទី២ (តារាងសរុបចំណាយថវិការបស់ថ្នាក់រដ្ឋបាលថ្នាក់នីមួយៗ)។

ថ្នាក់រដ្ឋបាលនីមួយៗ នៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវដកស្រង់ខ្លឹមសារចំណាត់ថ្នាក់នៃមាតិកាថវិកាណាដែលមានការពាក់ព័ន្ធដើម្បីរៀបចំគម្រោងថវិការបស់ខ្លួន និងផ្ញើជូនទៅតាមការកំណត់ដូចខាងក្រោម៖

រដ្ឋបាលសង្កាត់ត្រូវផ្ញើជូនគម្រោងថវិកាដែលក្រុមប្រឹក្សាសង្កាត់បានអនុម័តរួចទៅរដ្ឋបាលក្រុង និងរដ្ឋបាលរាជធានីយ៉ាងយឺតបំផុតត្រឹមថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៣។

រដ្ឋបាលខណ្ឌត្រូវផ្ញើជូនគម្រោងថវិកាដែលក្រុមប្រឹក្សាខណ្ឌបានអនុម័តរួចទៅរដ្ឋបាលរាជធានីយ៉ាងយឺតបំផុតត្រឹមថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៣។

រដ្ឋបាលឃុំត្រូវផ្ញើជូនគម្រោងថវិកាដែលក្រុមប្រឹក្សាឃុំបានអនុម័តរួចទៅរដ្ឋបាលខេត្ត និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៣។

រដ្ឋបាលក្រុងត្រូវផ្ញើគម្រោងថវិកា (រួមបញ្ចូលទាំងគម្រោងថវិកាសង្កាត់) ដែលក្រុមប្រឹក្សាក្រុងបានអនុម័តទៅរដ្ឋបាលខេត្ត និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៣។

រដ្ឋបាលខេត្តត្រូវផ្ញើគម្រោងថវិកាដែលក្រុមប្រឹក្សាខេត្តបានអនុម័តរួចទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៣។

រដ្ឋបាលរាជធានីត្រូវផ្ញើគម្រោងថវិកា(រួមបញ្ចូលគម្រោងថវិកាខណ្ឌនិងសង្កាត់)ដែលក្រុមប្រឹក្សារាជធានីបានអនុម័តរួចទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៣។

មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំកម្មវិធីដោយសម្របសម្រួលជាមួយអភិបាលនៃគណៈអភិបាលខេត្តដើម្បីពិនិត្យនិងបញ្ជាក់នីត្យានុកូលភាពលើគម្រោងថវិការបស់រដ្ឋបាលក្រុង ស្រុកដោយមានការចូលរួមពីមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្តត្រូវធ្វើការបូកសរុបថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិប្រចាំរាជធានី ខេត្តនីមួយៗតាមគំរូតារាងឧបសម្ព័ន្ធទី១«ក»,១«ខ» និង ១«គ»(តារាងសរុបចំណូលថវិការបស់រាជធានី ខេត្ត ក្រុង) និងគំរូតារាងឧបសម្ព័ន្ធទី២«ក»,២«ខ»និង ២«គ» (តារាងសរុបចំណាយថវិការបស់រាជធានី ខេត្ត ក្រុង) និងផ្ញើជូនមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៣។

ការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវគោរពទៅតាមគោលការណ៍តុល្យភាពនៃថវិកា។ រាល់ការវិភាជន៍ខ្ទង់ចំណាយលម្អិតទាំងអស់ត្រូវស្ថិតក្នុងក្របខ័ណ្ឌដែលគម្រោងចំណូលសរុបអាចធានារ៉ាប់រងបានជាក់ស្តែង អាណាប័កនិងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ត្រូវធ្វើការគិតគូររៀបចំគម្រោងចំណូលសរុបដើម្បីធ្វើជាមូលដ្ឋានក្នុងការវិភាជន៍គម្រោងចំណាយ។

## ក- អំពីគម្រោងចំណូល

ចំណូលក្នុងស្រុកថវិការដ្ឋឆ្នាំ២០១៤ ត្រូវសម្រេចឲ្យបាន១៥,២៣% នៃផ.ស.ស(ថ្នាក់ជាតិ១៤,២៤% និងថ្នាក់ក្រោមជាតិ០,៩៩%)។ ចំណូលចរន្តថវិការដ្ឋដែលត្រូវសម្រេចឲ្យបាន១៥,០៦% នៃផ.ស.ស គឺចំណូលពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាត្រូវសម្រេចឲ្យបាន៦,៧០%នៃផ.ស.ស ចំណូលពីអគ្គនាយកដ្ឋានពន្ធដារត្រូវសម្រេចឲ្យបាន៥,៩០%នៃផ.ស.ស (ថ្នាក់ជាតិ៤,៩៦%និងថ្នាក់ក្រោមជាតិ០,៩៤%)។

### ក-១- គម្រោងចំណូលចរន្ត

**ក-១-១-** ថ្នាក់រដ្ឋបាលរាជធានី ខេត្ត ការរៀបចំគម្រោងចំណូលត្រូវបានរៀបចំលើមូលដ្ឋានប្រភពចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធដែលបានកំណត់ដោយច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងលិខិតបទប្បញ្ញត្តិច្បាប់ទាំងឡាយជាធរមាន ។

-ចំណូលសារពើពន្ធ ត្រូវបានគិតគូរដោយផ្អែកលើ ៖

+ លទ្ធផលដែលសម្រេចបានក្នុងឆ្នាំកន្លងមក

+ លទ្ធផលដែលទទួលបាន និងការប៉ាន់ស្មានលទ្ធផលសរុបដែលអាចសម្រេចបានក្នុងឆ្នាំកំពុងអនុវត្ត
+ ផលប៉ះពាល់នៃអតិផរណាមកលើមូលដ្ឋានគិតពន្ធ
+ ប៉ាន់ស្មានលើការវិវត្តសេដ្ឋកិច្ចនៅពេលខាងមុខ
+ ការប្រែប្រួលដែលអាចកើតមានឡើងដោយអត្រា និងចំនួនមូលដ្ឋានប្រមូលពន្ធ
+ ចំណូលដែលសង្ឃឹមថាបានមកពីការបង្កើតប្រភេទពន្ធថ្មី ។

- ចំណូលមិនមែនសារពើពន្ធ ត្រូវបានគិតគូរដោយផ្អែកលើ ៖
+ កិច្ចការទាំងឡាយដែលនាំឲ្យមានផលទុនចំណូលដូចជា កិច្ចសន្យាជួល សៀវភៅបន្ទុកសេវាកម្ម និងការកែលម្អការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
+ ស្ថិតិមុខសញ្ញាប្រមូលក្នុងឆ្នាំកំពុងអនុវត្តនិងការវិវត្តសេដ្ឋកិច្ចដែលនាំមកនូវមុខសញ្ញាចំណូលថ្មី
+ ស្ថិតិបំណុលដែលពុំទាន់បានដោះស្រាយ

**ក-១-១-១-** ដោយឡែកចំពោះគម្រោងចំណូលសរុបរបស់រដ្ឋបាលរាជធានី ត្រូវរួមបញ្ចូលទាំងគម្រោងចំណូលរបស់ខណ្ឌ និងសង្កាត់ទាំងអស់ចំណុះរដ្ឋបាលរាជធានីដែលបានពីការវិភាជន៍និងផ្ទេរមកពីមូលនិធិឃុំ សង្កាត់នៅថ្នាក់ជាតិ និងចំណូលដែលរដ្ឋបាលខណ្ឌ និងសង្កាត់ប្រមូលបានដោយខ្លួនឯង។

លើមូលដ្ឋានកញ្ចប់គម្រោងចំណូលថវិកាប្រចាំឆ្នាំដែលបានកំណត់រួច អភិបាលនៃគណៈអភិបាលរាជធានីត្រូវធ្វើការបែងចែក និងជូនដំណឹងអំពីកញ្ចប់ថវិការបស់ខណ្ឌ និងសង្កាត់នីមួយៗ ដើម្បីរៀបចំគម្រោងថវិកាលម្អិតរបស់ខ្លួន ។

**ក-១-១-២-** ការបែងចែកកញ្ចប់ថវិកាសម្រាប់ខណ្ឌនីមួយៗត្រូវផ្អែកលើ ៖
- កញ្ចប់ថវិការបស់ខណ្ឌនីមួយៗដែលបានប្រើប្រាស់ក្នុងឆ្នាំកន្លងមក
- តម្រូវការចាំបាច់មួយចំនួនរបស់ខណ្ឌនីមួយៗដែលបានកំណត់ជាធរមាន
- តម្រូវការក្នុងការអនុវត្តមុខងារដែលអភិបាលនៃគណៈអភិបាលរាជធានីពិនិត្យឃើញថាសមស្របត្រូវធ្វើប្រតិភូកម្មទៅឲ្យអភិបាលនៃគណៈអភិបាលខណ្ឌនីមួយៗ។

**ក-១-១-៣-** ការបែងចែកកញ្ចប់ថវិកាសម្រាប់សង្កាត់នីមួយៗត្រូវផ្អែកលើ ៖
- កញ្ចប់មូលនិធិសង្កាត់នីមួយៗដែលទទួលបានពីការវិភាជន៍មូលនិធិឃុំ សង្កាត់ពីថ្នាក់ជាតិ
- ចំណូលដែលរដ្ឋបាលសង្កាត់ប្រមូលបានដោយខ្លួនឯង
- តម្រូវការក្នុងការអនុវត្តមុខងារដែលអភិបាលនៃគណៈអភិបាលរាជធានីពិនិត្យឃើញថាសមស្របត្រូវធ្វើប្រតិភូកម្មទៅឲ្យចៅសង្កាត់នីមួយៗ។

**ក-១-២-** ថ្នាក់រដ្ឋបាលក្រុង ស្រុក ការរៀបចំគម្រោងចំណូលត្រូវផ្អែកលើតួលេខដែលបានវិភាជន៍និងផ្ទេរមកពីថ្នាក់ជាតិនូវមូលនិធិក្រុង ស្រុក ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានជូនដំណឹង និងចំណូលដែលរដ្ឋបាល

ក្រុង ស្រុករកបានដោយខ្លួនឯង។ នៅឆ្នាំខាងមុខ រដ្ឋបាលក្រុង ស្រុកនឹងទទួលបាននូវប្រភពចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធដែលកំណត់ដោយលិខិតបទដ្ឋាន និងបទប្បញ្ញត្តិច្បាប់ដោយឡែក។

ដោយឡែកចំពោះគម្រោងចំណូលសរុបរបស់ក្រុង ត្រូវរួមបញ្ចូលទាំងចំណូលរបស់សង្កាត់ទាំងអស់ចំណុះរដ្ឋបាលក្រុងដែលបានវិភាជន៍និងផ្ទេរមកពីមូលនិធិឃុំ សង្កាត់នៅថ្នាក់ជាតិ និងចំណូលដែលរដ្ឋបាលសង្កាត់ប្រមូលបានដោយខ្លួនឯង។

លើមូលដ្ឋានកញ្ចប់គម្រោងចំណូលថវិកាប្រចាំឆ្នាំដែលបានកំណត់រួច អភិបាលនៃគណៈអភិបាលក្រុងត្រូវធ្វើការបែងចែកនិងជូនដំណឹងអំពីកញ្ចប់ថវិការបស់សង្កាត់នីមួយៗដើម្បីរៀបចំគម្រោងថវិកាលម្អិតរបស់ខ្លួន។

**ក-១-៣-** ថ្នាក់រដ្ឋបាលខណ្ឌ និងសង្កាត់ចំណុះរាជធានី ការរៀបចំគម្រោងចំណូលត្រូវផ្អែកលើកញ្ចប់ថវិកាដែលបានបែងចែកនិងជូនដំណឹងពីរដ្ឋបាលរាជធានី។

**ក-១-៤-** ថ្នាក់រដ្ឋបាលសង្កាត់ចំណុះក្រុង ការរៀបចំគម្រោងចំណូលត្រូវផ្អែកលើកញ្ចប់ថវិកាដែលបានបែងចែក និងជូនដំណឹងពីរដ្ឋបាលក្រុង។

**ក-១-៥-** ថ្នាក់រដ្ឋបាលឃុំ ការរៀបចំគម្រោងចំណូលត្រូវផ្អែកលើតួលេខដែលបានវិភាជន៍ និងផ្ទេរពីថ្នាក់ជាតិនូវមូលនិធិឃុំ សង្កាត់ដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានជូនដំណឹងតាមរយៈរដ្ឋបាលខេត្តនិងចំណូលរដ្ឋបាលផ្សេងៗដែលប្រមូលបាននៅមូលដ្ឋានរបស់ឃុំ។

### ក-២- គម្រោងចំណូលមូលធន

ចំណូលជាមូលធននៃថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗអាចបានមកពីការផ្ទេរឥណទានពីថវិកាថ្នាក់ជាតិ និងចំណូលមូលធនដែលមានប្រភពនៅនឹងមូលដ្ឋានផ្ទាល់។ ដូចនេះពេលរៀបចំគម្រោងចំណូលជាមូលធនគ្រប់ថ្នាក់នីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវយកចិត្តទុកដាក់កត់ត្រាបញ្ចូលឲ្យអស់នូវជំនួយមនុស្សធម៌និងជំនួយពីបរទេសដែលសប្បុរសជន អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលនានាបានសន្យាផ្តល់ហិរញ្ញប្បទានផ្ទាល់ដល់ថវិការបស់រដ្ឋបាលនីមួយៗរួចហើយ។

## ខ- អំពីគម្រោងចំណាយ

ចំណាយសរុបថវិការដ្ឋឆ្នាំ២០១៤ ត្រូវរក្សាឲ្យនៅត្រឹម២០,១៣% នៃផ.ស.ស (ថ្នាក់ជាតិ១៩,៣៣% និងថ្នាក់ក្រោមជាតិ០,៩៩%) ដោយចំណាយចរន្តថវិការដ្ឋនឹងកម្រិតត្រឹម១២,០៦%នៃផ.ស.ស(ថ្នាក់ជាតិ ១១,៤៧% និងថ្នាក់ក្រោមជាតិ០,៧៨%) ក្នុងនោះរាជរដ្ឋាភិបាលកំពុងរៀបចំកែលម្អប្រព័ន្ធបៀវត្ស និងរៀបចំគោលនយោបាយដំឡើងប្រាក់បៀវត្សដោយផ្អែកលើកំណើនសេដ្ឋកិច្ច អតិផរណា និងលទ្ធភាពថវិកា ក្នុងទិសដៅលើកកម្ពស់ផលិតភាពការងារ បង្កើនប្រសិទ្ធិភាពនៃការផ្តល់សេវាសាធារណៈ និងធានាបាននូវសមធម៌ ព្រមទាំងរក្សាបាននូវស្ថេរភាព និងចីរភាពហិរញ្ញវត្ថុសាធារណៈ និងម៉ាក្រូសេដ្ឋកិច្ច។ ថវិការាជធានី ខេត្ត ត្រូវកំណត់ត្រឹម

0,៩៩% នៃ ផ.ស.ស ដែលក្នុងនោះថវិកាផ្ទាល់របស់រាជធានី ខេត្តសរុបមានប្រមាណ0,៧៩% នៃផ.ស.ស មានកំណើន0,0៩% នៃផ.ស.ស ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ និងថវិកាឧបត្ថម្ភពីថ្នាក់ជាតិដល់រាជធានី ខេត្ត និងក្រុង ស្រុក ស្មើនឹង0,២0% នៃផ.ស.ស ដែលក្នុងនោះថវិកាដែលត្រូវផ្ទេរសម្រាប់មូលនិធិក្រុង ស្រុកសម្រាប់ឆ្នាំ២០១៤ ត្រូវបានកំណត់ស្មើនឹង 0,៨% នៃចំណូលចរន្តថវិកាថ្នាក់ជាតិឆ្នាំ២០១៣។

ថ្នាក់រដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវដំណើរការរៀបចំគម្រោងចំណាយថវិកាដោយផ្អែកលើគោលការណ៍ដូចខាងក្រោម ៖

- ត្រូវស្ថិតក្នុងក្របខ័ណ្ឌដែលលទ្ធភាពសរុបចំណូលអាចធានារ៉ាប់រងបាន
- ត្រូវបានរៀបចំដោយវិចារណកម្មទៅតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាដែលមានការពាក់ព័ន្ធ
- ត្រូវលម្អិតទៅតាមជំពូក គណនី និងអនុគណនីស្របតាមខ្លឹមសារចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាដែលមានការពាក់ព័ន្ធនិងទៅតាមលំដាប់លំដោយនៃអាទិភាពចំណាយ។

## ខ-១- គម្រោងចំណាយរបស់រដ្ឋបាលរាជធានី ខេត្ត

ក្របខណ្ឌថវិកាបានគ្រោងចំណូល-ចំណាយថ្នាក់ក្រោមជាតិជារួម ឲ្យមានតុល្យភាព ដោយពុំមានការចាំបាច់ក្នុងការឧបត្ថម្ភពីថ្នាក់ជាតិ ដល់រាជធានី ខេត្តទេ។ ទោះជាយ៉ាងណាក្តី យើងនៅមានបញ្ហាប្រឈមមួយគឺការផ្ទេរធនធានពីខេត្តមានអតិរេក ទៅខេត្តឱនភាព គឺជាការលំបាក។ ដើម្បីដោះស្រាយបញ្ហានេះ ថវិការាជធានីខេត្តនីមួយៗ មិនអាចមានកំណើនស្មើគ្នាបានឡើយ ដោយខេត្តមានចំណូលខ្ពស់ដូចជារាជធានីភ្នំពេញ ឬខេត្តសៀមរាប គួរត្រូវបានអនុញ្ញាតឲ្យបង្កើនចំណាយលើសពីកំណើនមធ្យមភាគ ២១,២%។ ដោយឡែក ខេត្តមានចំណូលទាបអនុញ្ញាតឲ្យមានកំណើនទាបជាង ព្រោះត្រូវបានឧបត្ថម្ភថវិកាពីថ្នាក់ជាតិ។

**ខ-១-១-** គម្រោងចំណាយរបស់រដ្ឋបាលរាជធានីត្រូវបានរៀបចំលម្អិតតាមជំពូក គណនី និងអនុគណនីស្របតាមខ្លឹមសារចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា ដែលមានការពាក់ព័ន្ធដោយផ្អែកលើមូលដ្ឋានសរុបចំណូលក្រោយពីបានដកចេញនូវកញ្ចប់ថវិកាខណ្ឌនិងកញ្ចប់ថវិកាសង្កាត់ចំណុះរាជធានីរួចហើយ នឹងត្រូវបានបូកបញ្ចូលជាមួយគម្រោងចំណាយរបស់រដ្ឋបាលខណ្ឌនិងសង្កាត់ក្រោយពេលដែលរដ្ឋបាលខណ្ឌ និងសង្កាត់បានផ្ញើជូននូវគម្រោងថវិកាដែលក្រុមប្រឹក្សារបស់ខ្លួនបានអនុម័តរួច។

**ខ-១-២-** គម្រោងចំណាយរបស់រដ្ឋបាលខេត្ត ត្រូវបានរៀបចំលម្អិតតាមជំពូក គណនី និងអនុគណនីស្របតាមខ្លឹមសារចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា ដែលមានការពាក់ព័ន្ធដោយផ្អែកលើគម្រោងចំណូលសរុបដែលបានគណនារួច។

## ខ-២- គម្រោងចំណាយរបស់រដ្ឋបាល ក្រុង ស្រុក ខណ្ឌ

**ខ-២-១-** គម្រោងចំណាយរបស់រដ្ឋបាល ក្រុង ត្រូវបានរៀបចំលម្អិតទៅតាមជំពូក គណនី និងអនុគណនី ស្រប

តាមខ្លឹមសារចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា ដែលមានការពាក់ព័ន្ធដោយផ្អែកលើមូលដ្ឋានសរុបចំណូល ក្រោយពីបានដកចេញនូវកញ្ចប់ថវិកាសង្កាត់ចំណុះក្រុងរួចហើយ នឹងត្រូវធ្វើការបូកបញ្ចូលជាមួយគម្រោងចំណាយរបស់រដ្ឋបាលសង្កាត់ក្រោយពេលដែលសង្កាត់ចំណុះក្រុង បានធ្វើជូនគម្រោងថវិកាដែលក្រុមប្រឹក្សារបស់ខ្លួនបានអនុម័តរួច។

**ខ-២-២-** គម្រោងចំណាយរបស់រដ្ឋបាល ស្រុក ត្រូវបានរៀបចំលម្អិតទៅតាមជំពូក គណនី និង អនុគណនី ស្របតាមខ្លឹមសារចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាដែលមានការពាក់ព័ន្ធដោយផ្អែកលើមូលដ្ឋានសរុបចំណូលដែលបានគណនារួច។

**ខ-២-៣-** គម្រោងចំណាយរបស់រដ្ឋបាល ខណ្ឌ ត្រូវបានរៀបចំលម្អិតទៅតាមជំពូក គណនី និងអនុគណនី ស្របតាមខ្លឹមសារចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាដែលមានការពាក់ព័ន្ធ ដោយផ្អែកលើមូលដ្ឋានកញ្ចប់ថវិកាដែលរដ្ឋបាលរាជធានីបានជូនដំណឹង។

## ខ-៣- គម្រោងចំណាយរបស់រដ្ឋបាលឃុំ សង្កាត់

**ខ-៣-១-** គម្រោងចំណាយរបស់រដ្ឋបាល ឃុំ ត្រូវបានរៀបចំលម្អិតទៅតាមជំពូក គណនី និងអនុគណនីស្របតាមខ្លឹមសារចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាដោយផ្អែកលើមូលដ្ឋានសរុបចំណូលដែលបានគណនារួច។

**ខ-៣-២-** គម្រោងចំណាយរបស់រដ្ឋបាល សង្កាត់ ត្រូវបានរៀបចំលម្អិតទៅតាមជំពូក គណនី និងអនុគណនី ស្របតាមខ្លឹមសារចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាដែលមានការពាក់ព័ន្ធដោយផ្អែកលើមូលដ្ឋានកញ្ចប់ថវិកាដែលរដ្ឋបាលរាជធានី និងរដ្ឋបាលក្រុងបានជូនដំណឹង។

## គ- ការរៀបចំគម្រោងចំណាយ

ចំណាយទាំងអស់ត្រូវតែមានការវិភាគ និងមានលិខិតយុត្តិការភ្ជាប់មកជាមួយតាមជំពូក គណនី អនុគណនី ដើម្បីបង្ហាញឲ្យឃើញថាការគិតគូរចំណាយរបស់ខ្លួនមានភាពត្រឹមត្រូវហ្មត់ចត់ និងសមហេតុផល ហើយលិខិតយុត្តិការទាំងអស់នេះ ទុកសម្រាប់ធ្វើជាមូលដ្ឋានលើការពិនិត្យនីត្យានុកូលភាពនៃថវិកា។

## គ-១- ការរៀបចំគម្រោងចំណាយចរន្ត

### គ-១-១- ប្រភេទ ១ ៖ មធ្យោបាយសេវា

### គ-១-១-១- ជំពូក ៦២ និង ៦៤ សេវាខាងក្រៅផ្សេងៗនិងបន្ទុកបុគ្គលិក

ចំណាយសម្រាប់បុគ្គលិកត្រូវតែ គិតគូរឲ្យបានច្បាស់លាស់។ ចំណាយលើជំពូក ៦៤ ត្រូវបានចាត់ទុកជាចំណាយដែលមានអាទិភាពបំផុតក្នុងការរៀបចំគម្រោងថវិកា។

ចំណាយបុគ្គលិក (ជំពូក ៦៤) ត្រូវគ្រោងទៅតាមតារាងប្រព័ន្ធប្រាក់បៀវត្សនៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលសាធារណៈ និងតាមចំនួនមន្ត្រីរាជការដែលមានជាក់ស្តែងក្នុងឆ្នាំ២០១៣។ រាជរដ្ឋាភិបាលបាន

គ្រោងកញ្ចប់ថវិការួមមួយសម្រាប់ដំឡើងបៀវត្សឆ្នាំ២០១៤ ប៉ុន្តែដោយសាររាជរដ្ឋាភិបាលកំពុងរៀបចំក្របខ័ណ្ឌ និងយុទ្ធសាស្ត្រសម្រាប់ការដំឡើងប្រកបដោយសមធម៌ សង្គតិភាព និងប្រសិទ្ធភាព ជាពិសេសដើម្បីធានាឲ្យមានគំលាតសមស្របរវាងអ្នកមានបៀវត្សខ្ពស់ និងទាប ព្រមទាំងធានាស្ថេរភាព និងចីរភាពថវិកា ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ និងម៉ាក្រូសេដ្ឋកិច្ចគ្រប់ក្រសួងស្ថាប័ន ត្រូវគ្រោងទៅតាមមូលដ្ឋាននៃក្របខ័ណ្ឌបៀវត្សបច្ចុប្បន្នសិន នៅពេលដែលក្របខ័ណ្ឌ និងយុទ្ធសាស្ត្រនៃការអនុវត្តប្រព័ន្ធបៀវត្សថ្មីត្រូវបានអនុម័ត រាជរដ្ឋាភិបាលនឹងបំពេញបន្ថែមនូវថវិកាសម្រាប់ការអនុវត្តតាមក្របខ័ណ្ឌថ្មីនៃប្រព័ន្ធបៀវត្ស ដល់គ្រប់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ចំពោះមន្ត្រីរាជការដែលត្រូវជ្រើសរើសបន្ថែមថ្មី ត្រូវគ្រោងដោយផ្អែកលើសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល និងតាមសំណើរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងមានទិដ្ឋាការរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ ផ្ទេរចេញ ឬលាឈប់ពីក្របខ័ណ្ឌរដ្ឋ និងមរណៈភាពត្រូវកាត់ចេញពីអង្គភាពរបស់ខ្លួន និងមិនត្រូវគ្រោងទេ។ ចំពោះការឡើងឋានៈ និងកាំប្រាក់ត្រូវគ្រោងដោយឡែក និងដោយផ្អែកលើលិខិតយុត្តិការផ្លូវការរបស់រាជរដ្ឋាភិបាល។ មិនត្រូវគិតអតិផរណានៅក្នុងការគ្រោងចំណាយបៀវត្សនេះទេ។

ការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំចំនួនមន្ត្រីរាជការ ពលករអណ្តែតនិងមន្ត្រីជាប់កិច្ចសន្យាដែលកំពុងបំពេញការងារនៅតាមរដ្ឋបាលក្រុង ស្រុក ខណ្ឌ នីមួយៗដែលរួមទាំងមន្ត្រីស្មៀនឃុំ ផងនោះ ហើយបានអនុវត្តតាមគំរូតារាងដែលមានខ្លឹមសារដូចនឹងតារាងប្រាក់បៀវត្សរបស់ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលសាធារណៈឆ្នាំមុនត្រូវបន្តអនុវត្តទៀត ដើម្បីដាក់ជូនអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌចុះហត្ថលេខាបោះត្រាបញ្ជាក់។ ចំពោះចំនួនមន្ត្រីរាជការបន្ថែមថ្មីត្រូវគ្រោងដោយផ្អែកលើសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលតាមសំណើរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងមានទិដ្ឋាការរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ ផ្ទេរចេញ ឬលាឈប់ពីក្របខ័ណ្ឌរដ្ឋ និងមរណៈភាពត្រូវកាត់ចេញពីអង្គភាពរបស់ខ្លួន។

ចំពោះប្រាក់បំណាច់មុខងារអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវគ្រោងនៅក្នុងអនុគណនី ៦៤១១ ប្រាក់បំណាច់មុខងារអភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវគ្រោងនៅក្នុងអនុគណនី ៦៤១២និងប្រាក់បំណាច់មុខងារមន្ត្រីរាជការត្រូវគ្រោងក្នុងអនុគណនី៦៤២២។ ចំពោះប្រាក់បៀវត្សមូលដ្ឋានរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ត្រីរាជការត្រូវគ្រោងនៅក្នុងអនុគណនី ៦៤២១។

ចំពោះគម្រោងប្រាក់ឧបត្ថម្ភរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងមន្ត្រីភូមិត្រូវគ្រោងនៅក្នុងជំពូក៦៤ គណនី៦៤៤ (លោកការផ្សេងៗទៀតបុគ្គលិកមិនមែនក្របខណ្ឌអនុគណនី ៦៤៤២ ប្រាក់ឧបត្ថម្ភក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងអនុគណនី៦៤៤៥ ប្រាក់ឧបត្ថម្ភមន្ត្រីភូមិ) ប្រាក់ឧបត្ថម្ភចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានកំណត់តាមអនុក្រឹត្យលេខ ២១៤ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩។ ចំពោះប្រាក់បំណាច់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រាក់ឧបត្ថម្ភមេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ត្រូវគ្រោងបង្កើនមួយរយភាគរយ។

ក្នុងករណីដែលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានតម្រូវការអំពីពលករអណ្តែតត្រូវគ្រោងនៅក្នុងជំពូក៦៤ គណនី៦៤៤ អនុគណនី៦៤៤៣ (បៀវត្សមូលដ្ឋាន បុគ្គលិកអណ្តែត) និងមន្ត្រីជាប់កិច្ចសន្យាការងារឯកទេសដែលត្រូវចុះកិច្ចសន្យាអនុវត្តសម្រាប់រយៈពេលខ្លីជាកំណត់ត្រូវគ្រោងនៅក្នុងជំពូក៦៤ គណនី៦៤៤ អនុគណនី៦៤៤១ (បៀវត្សមូលដ្ឋានបុគ្គលិកមិនមែនក្របខណ្ឌ)។

ចំនួនបុគ្គលិកទាំងអស់ ដែលស្ថិតនៅក្រោមឱវាទរបស់ថ្នាក់រដ្ឋបាលនីមួយៗត្រូវបូកសរុបនៅក្នុងតារាងទី១ និងចំនួនក្រុមប្រឹក្សាទាំងអស់ត្រូវបូកសរុបនៅក្នុងតារាងទី១«ក» ដែលបានភ្ជាប់ជូនមកជាមួយនេះ។ សលាកប័ត្រនេះមានចែកជាច្រើនខ្ទង់សម្រាប់កត់ត្រានូវប្រភេទបុគ្គលិកទាំងអស់ដែលថ្នាក់រដ្ឋបាលនីមួយៗមាន។

បុគ្គលិក មន្ត្រីរាជការដែលលម្អិតទៅតាមអង្គភាពនីមួយៗ ហើយចំនួននេះត្រូវតែផ្ទៀងផ្ទាត់ជាមួយនិងចំនួនដែលមាននៅក្នុងតារាងសរុបចំណាយ ( តាមតារាងប្រព័ន្ធប្រាក់បៀវត្សរបស់ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល)។

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវលម្អិតចំនួនបុគ្គលិកទៅតាមរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនីមួយៗដែលស្ថិតនៅក្រោមឱវាទរបស់ខ្លួន។

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សង្កាត់ ត្រូវគ្រោងលម្អិតជំពូក៦២ សេវាខាងក្រៅផ្សេងៗទៀតនៅក្នុងតារាងទី២ ដូចជាចំណាយទទួលភ្ញៀវ បេសកកម្ម ទូរស័ព្ទ ពិធីបុណ្យផ្សេងៗ គណៈបញ្ជាការឯកភាព......។

**គ-១-១-២- ជំពូក ៦០ និង ៦១ (ការទិញ សេវាខាងក្រៅ)**

ប្រមូលផ្តុំរាល់ការចំណាយដំណើរការរដ្ឋបាល ទិញសម្ភារៈ ជួសជុលតូច និងចំណាយជាគុណប្រយោជន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវគ្រោងនៅក្នុងតារាងទី៣ និងតារាងទី៤។ ឥណទានចំណាយក្នុងជំពូកនេះ ចែកចេញជាពីរផ្នែកសំខាន់ៗ ៖

មួយផ្នែកជាឥណទានសម្រាប់បម្រើឲ្យកិច្ចប្រតិបត្តិការរដ្ឋបាលសុទ្ធសាធ ដែលចាំបាច់ត្រូវគិតគូរឲ្យបានហ្មត់ចត់ និងត្បិតត្បៀតសន្សំសំចៃ ដោយផ្អែកលើគោលការណ៍រួមរបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងចំណាយសាធារណៈ។ ក្នុងឆ្នាំ២០១៤ឥណទានចំណាយផ្នែកនេះគឺអនុញ្ញាតឲ្យគ្រោងក្នុងកំរិតប្រហាក់ប្រហែលនឹងឆ្នាំ២០១៣ តែប៉ុណ្ណោះ។

ដោយឡែកថ្លៃឈ្នួល និងបន្ទុក (គណនី ៦១៣) គឺអនុញ្ញាតឲ្យគ្រោងតែចំណាយសម្រាប់ជួលស្នាក់ការរដ្ឋបាលតែប៉ុណ្ណោះ។

មួយផ្នែកទៀតជាឥណទានសម្រាប់បម្រើដល់គុណប្រយោជន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរៀបចំមូលដ្ឋានសម្ភារៈនៃសេវាសាធារណៈនិងការអភិវឌ្ឍ។ ផ្អែកលើផែនការយុទ្ធសាស្ត្រនិងផែនការអភិវឌ្ឍថ្នាក់រដ្ឋបាលនីមួយៗ ចាំបាច់ត្រូវរៀបចំទៅតាមលំដាប់លំដោយនៃអាទិភាពរបស់គម្រោងចំណាយអំពីការងារគុណប្រយោជន៍របស់ខ្លួន។

ទន្ទឹមនោះ ថ្នាក់រដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវយកចិត្តទុកដាក់បង្កើននូវចំណាយអភិវឌ្ឍ ក្នុងករណីដែលលទ្ធភាពចំណូលសម្រេចបានលើសផែនការ ព្រោះការអភិវឌ្ឍនៅមូលដ្ឋានគឺជាគោលបំណងនៃគោលនយោបាយនិងជាទិសដៅយុទ្ធសាស្ត្រអាទិភាពខ្ពស់បំផុតរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ត្រូវគ្រោងឥណទានសម្រាប់ចំណាយជាគុណប្រយោជន៍រាជធានី ខេត្ត ក្រុង ស្រុកតាមការងារនីមួយៗ (បំភ្លឺសាធារណៈ ប្រមូលសំរាម អនាម័យ សន្តិសុខ ប្រឆាំងអគ្គិភ័យ ការផ្គត់ផ្គង់ទឹក....) និងតាមការដ្ឋាននីមួយៗ (ផ្លូវថ្នល់ ស្ពាន សួនច្បារ លូទឹក ប្រឡាយ...) ដោយមានបញ្ជាក់អំពីបញ្ជីប៉ាន់តម្លៃ និងទីតាំងច្បាស់លាស់ដែលជាឯកសារសម្រាប់ការពិភាក្សាថវិកាប្រចាំឆ្នាំ។

ជាទូទៅចំណាយដំណើរការរដ្ឋបាល ទិញសម្ភារៈ ការថែទាំ និងការជួសជុលតូច ត្រូវគិតគូរទៅតាមតម្រូវការនៃកម្មវិធីសកម្មភាពឬទៅតាមបទដ្ឋានសមស្រប។ ម្យ៉ាងទៀតរាជធានី ខេត្ត ក្រុង ស្រុក មិនត្រូវគ្រោងបំប៉ោងឥណទានដែលស្នើសុំសម្រាប់ចំណាយប្រភេទនេះទេ។ ឥណទានសម្រាប់ចំណាយរដ្ឋបាលអចិន្ត្រៃយ៍ ដូចជា ទូរស័ព្ទ អគ្គិសនី ទឹក សម្ភារៈការិយាល័យ ប្រេងឥន្ធនៈ និងការទទួលភ្ញៀវត្រូវគិតគូរក្នុងកំរិតប្រហាក់ប្រហែលនិងឆ្នាំ២០១៣ និងត្រូវគ្រប់គ្រងយ៉ាងម៉ឺងម៉ាត់ ដើម្បីសន្សំសំចៃលើចំណាយប្រភេទនេះ ជាពិសេសឥណទានសម្រាប់ចំណាយអគ្គិសនី ទឹក សម្រាប់គុណប្រយោជន៍របស់រាជធានី ខេត្ត ក្រុង ស្រុក ត្រូវគ្រោងឲ្យបានគ្រប់គ្រាន់សម្រាប់តម្រូវការក្នុងឆ្នាំ និងការសងបំណុល។ ក្នុងករណីដែលរាជធានី ខេត្ត ក្រុង ស្រុក គ្រោងមិនបានគ្រប់គ្រាន់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងធ្វើនិយ័តភាពឥណទានផ្ទៃក្នុងជំពូកថវិការបស់រាជធានី ខេត្ត ក្រុង ស្រុក ហើយដាក់កម្មវិធីចំណាយសម្រាប់ទូទាត់ជូនរាជធានី ខេត្ត ក្រុង ស្រុកដោយស្វ័យប្រវត្តិ។ ចំពោះគម្រោងថវិការបស់រដ្ឋបាលក្រុង ស្រុក រៀបចំមិនត្រឹមត្រូវតាមគោលការណ៍ណែនាំខាងលើ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងធ្វើការកែតម្រូវថវិការបស់រដ្ឋបាលក្រុង ស្រុក ឡើងវិញឲ្យសមស្របតាមសារាចរណែនាំនេះ។

### គ-១-២- ប្រភេទ ៣ : ចំណាយអន្តរាគមន៍សាធារណៈ

#### គ-១-២-១- ជំពូក ៦៥ : ការឧបត្ថម្ភកធន និងជំនួយសង្គម

ចំណាយប្រភេទនេះត្រូវចែងលម្អិតឲ្យច្បាស់លាស់នូវគោលដៅដែលត្រូវសម្រេច។ ត្រូវពិនិត្យជ្រើសរើសចំណាយប្រភេទនេះឲ្យបានហ្មត់ចត់ដោយផ្អែកលើលក្ខណៈសម្បត្តិនៃអ្នកដែលទទួលផល និងចំនួនទឹកប្រាក់ដែលត្រូវពិនិត្យផ្តល់ជូន(គម្រោងចំណាយនេះត្រូវសរុបតារាងទី៥)។

### គ-១-៣-ប្រភេទ៤ : ចំណាយផ្សេងៗ

#### គ-១-៣-១- ជំពូក ៦៣ : (ពន្ធ និងអាករ)

ចំណាយប្រភេទនេះ គឺសម្រាប់កាតព្វកិច្ចពន្ធដូចជាចំណាយលើអាករ (លតាប័ត្រលើរថយន្ត ម៉ូតូរបស់រដ្ឋ.......) ពន្ធប្រថាប់ត្រាសម្រាប់ទទួលកម្មសិទ្ធិ និងចំណាយបង់ពន្ធអាករផ្សេងៗទៀតតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (គម្រោងចំណាយនេះត្រូវសរុបតារាងទី៦)។

### គ-១-៤- ប្រភេទ ៦ : ចំណាយមិនបានគ្រោងទុក

#### គ-១-៤-១- ជំពូក ០៩ : (ចំណាយមិនបានគ្រោងទុក)

ចំណាយប្រភេទនេះ គឺជាការគិតគូរគ្រោងបម្រុងសម្រាប់ចំណាយចៃដន្យ ដែលអាចកើតមានជាយថាហេតុនៅក្នុងឆ្នាំអនុវត្ត។ សម្រាប់ឆ្នាំថវិកា២០១៤ ប្រភេទឥណទាននេះ គឺអនុញ្ញាតឲ្យគ្រោងពី៣ទៅ៥ភាគរយនៃ

គម្រោងចំណាយសរុបរបស់ថ្នាក់រដ្ឋបាលនីមួយៗ ហើយខ្ទង់ចំណាយនេះ ពេលអនុវត្តត្រូវស្នើសុំធ្វើនិយ័តភាពទៅបំពេញឲ្យជំពូកដទៃទៀតដែលតម្រូវការចំណាយចៃដន្យកើតមានឡើងជាយថាហេតុ និងតម្រូវការចំណាយសម្រាប់អភិវឌ្ឍរាជធានី ខេត្ត ក្រុង ស្រុក។

## គ-២- ការរៀបចំគម្រោងចំណាយជាមូលធន:

### គ-២-១- ប្រភេទ ២ : អចលកម្ម

### គ-២-១-១- ជំពូក ២០ និងជំពូក ២១ : (អចលកម្មអរូបី និងអចលកម្មរូបី)

ចំណាយជាមូលធន គឺជាចំណាយសម្រាប់ធ្វើហិរញ្ញប្បទានចំពោះគម្រោងវិនិយោគដែលមានការព្រមព្រៀងគ្នាជាមុន និងសំដៅធ្វើឲ្យសម្រេចតាមគោលដៅដែលបានដាក់ចេញ។

គម្រោងវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិអាចគ្រោងបានក្នុងករណីដែលរដ្ឋបាលថ្នាក់ក្រោមជាតិបានទទួលគោលការណ៍អនុញ្ញាតជាផ្លូវការឲ្យគ្រប់គ្រងហិរញ្ញប្បទានដោយផ្ទាល់។

ការវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេសដោយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិអាចគ្រោងបានក្នុងករណីដែលរដ្ឋបាលថ្នាក់ក្រោមជាតិមានអតិរេកចរន្តឬមានចំណូលជាមូលធនផ្ទៃក្នុងដោយផ្ទាល់ (គម្រោងចំណាយនេះត្រូវសរុបក្នុងតារាងទី៧)។

ការវិនិយោគដោយហិរញ្ញប្បទានពីបរទេសផ្ទាល់ត្រូវផ្អែកលើកម្មវិធីជំនួយឬគម្រោងការដែលអង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ឬម្ចាស់ជំនួយទ្វេភាគីមានបំណងផ្តល់ត្រង់ទៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកត់ត្រាចូលទៅក្នុងគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ទន្ទឹមនឹងនេះរដ្ឋបាលថ្នាក់ក្រោមជាតិក៏ត្រូវយកចិត្តទុកដាក់ផងដែរក្នុងការកត់ត្រារាល់ចំណាយថវិកាបដិភាគជាប្រាក់រៀលដែលត្រូវអនុវត្តជាមួយគម្រោងដោយហិរញ្ញប្បទានពីបរទេសផ្ទាល់។

គម្រោងវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបញ្ចូលទៅក្នុងគម្រោងថវិកាប្រចាំឆ្នាំគឺ ត្រូវផ្អែកលើកម្មវិធីវិនិយោគដែលបានធ្វើបច្ចុប្បន្នភាពនឹងត្រូវបានក្រុមប្រឹក្សាពិនិត្យអនុម័តចុងក្រោយគេបំផុត។

## ឃ- វិធីសាស្ត្រក្នុងការរៀបចំគម្រោងចំណូលចំណាយថវិកា

គម្រោងចំណូល ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំឡើងក្រោមការទទួលខុសត្រូវរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នឹងមេឃុំ ចៅសង្កាត់ ហើយត្រូវបានពិនិត្យនិងអនុម័តដោយក្រុមប្រឹក្សានៃថ្នាក់រដ្ឋបាលនីមួយៗ។

### ឃ-១- ការរៀបចំគម្រោងចំណូល

**ឃ-១-១-** នៅថ្នាក់រដ្ឋបាលរាជធានី ខេត្ត អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវអញ្ជើញប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានសាខាពន្ធដារ ប្រធានមន្ទីរជំនាញ និងអង្គភាពដែលមានការពាក់ព័ន្ធក្នុងការប្រមូលចំណូលសារពើពន្ធនិងចំណូលមិនមែនសារពើពន្ធមកពិភាក្សាគិតគូររៀបចំដើម្បីកំណត់ឲ្យបាននូវគម្រោង

សរុបចំណូលថវិកាប្រចាំឆ្នាំ២០១៤។ ចំពោះសាលារាជធានី ត្រូវមានការអញ្ជើញចូលរួមពីអភិបាលនៃគណៈអភិបាលខណ្ឌ និងចៅសង្កាត់ទាំងអស់ចំណុះរាជធានីដើម្បីលើកឡើងអំពីលទ្ធភាពប្រមូលចំណូលមិនមែនសារពើពន្ធនៅមូលដ្ឋាន និងចំណូលដែលសង្កាត់ចំណុះរាជធានីទទួលបានពីការវិភាជន៍មូលនិធិឃុំ សង្កាត់ ។

**ឃ-១-២-** នៅថ្នាក់ក្រុង ស្រុក អភិបាលនៃគណៈអភិបាលក្រុង ស្រុកដោយមានជំនួយពីប្រធានការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ និងប្រធានការិយាល័យច្រកចេញចូលតែមួយត្រូវព្យាករណ៍នូវលទ្ធភាពប្រមូលចំណូលមិនមែនសារពើពន្ធនៅមូលដ្ឋានបូករួមជាមួយចំណូលដែលទទួលបានពីការវិភាជន៍មូលនិធិក្រុង ស្រុក ដើម្បីកំណត់នូវកញ្ចប់គម្រោងសរុបចំណូលថវិកាប្រចាំឆ្នាំ២០១៤ របស់សាលាក្រុង ស្រុកផ្ទាល់។

ដោយឡែកចំពោះរដ្ឋបាលក្រុង ត្រូវមានការអញ្ជើញចូលរួមពីចៅសង្កាត់ទាំងអស់ចំណុះក្រុង ដើម្បីលើកឡើងអំពីលទ្ធភាពប្រមូលចំណូលមិនមែនសារពើពន្ធនៅមូលដ្ឋាន និងចំណូលដែលសង្កាត់ចំណុះក្រុងទទួលបានពីការវិភាជន៍មូលនិធិឃុំ សង្កាត់ឆ្នាំ២០១៤។

**ឃ-១-៣-** នៅថ្នាក់រដ្ឋបាលខណ្ឌ អភិបាលនៃគណៈអភិបាលខណ្ឌដោយមានជំនួយពីប្រធានការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ និងប្រធានការិយាល័យច្រកចេញចូលតែមួយ(បើមាន) ត្រូវព្យាករណ៍លទ្ធភាពប្រមូលចំណូលមិនមែនសារពើពន្ធនៅមូលដ្ឋានប្រចាំឆ្នាំ ដើម្បីរាយការណ៍នៅពេលទៅចូលរួមប្រជុំរៀបចំគម្រោងចំណូលប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី។

**ឃ-១-៤-** នៅថ្នាក់រដ្ឋបាលឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ត្រូវព្យាករណ៍អំពីលទ្ធភាពប្រមូលចំណូលមិនមែនសារពើពន្ធនៅមូលដ្ឋានបូករួមជាមួយចំណូលដែលទទួលបានការវិភាជន៍មូលនិធិឃុំ សង្កាត់ ដើម្បីកំណត់ឲ្យបាននូវកញ្ចប់គម្រោងសរុបចំណូលថវិកាប្រចាំឆ្នាំ។ ដោយឡែកចៅសង្កាត់ត្រូវរាយការណ៍អំពីគម្រោងសរុបចំណូលថវិកាប្រចាំឆ្នាំរបស់ខ្លួននៅពេលទៅចូលរួម រៀបចំគម្រោងចំណូលប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី និងក្រុង។

**ឃ-២- ការរៀបចំគម្រោងចំណាយ**

**ឃ-២-១-** នៅថ្នាក់រដ្ឋបាលរាជធានី ខេត្ត អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវរៀបចំប្រជុំដោយមានការចូលរួមពីនាយករដ្ឋបាល នាយកទីចាត់ការហិរញ្ញវត្ថុ និងមន្ត្រីជំនាញដែលទទួលបន្ទុករៀបចំគម្រោងចំណាយ ដើម្បីពិភាក្សា គណនាអំពីតម្រូវការ និងលំដាប់លំដោយនៃអាទិភាពចំណាយទាំងអស់ដើម្បីរៀបចំគម្រោងចំណាយដោយដាក់បញ្ចូលឲ្យបានត្រឹមត្រូវតាមខ្លឹមសារចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា។

ដោយឡែកគម្រោងចំណាយរបស់រដ្ឋបាលរាជធានីត្រូវបូកបញ្ចូលនូវគម្រោងចំណាយរបស់រដ្ឋបាលខណ្ឌ និងសង្កាត់ទាំងអស់ចំណុះរាជធានី ក្រោយពេលដែលរដ្ឋបាលខណ្ឌ និងសង្កាត់ទាំងនោះបានផ្ញើជូននូវគម្រោងថវិកាដែលក្រុមប្រឹក្សារបស់ខ្លួនបានអនុម័តរួច។

**ឃ-២-២-** នៅថ្នាក់រដ្ឋបាលក្រុង ស្រុក ខណ្ឌ អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំការប្រជុំដោយមានការចូលរួមពីនាយករដ្ឋបាល ប្រធានការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ និងមន្ត្រីជំនាញដែលទទួល

បន្ទុករៀបចំគម្រោងចំណាយដើម្បីពិភាក្សា គណនាអំពីតម្រូវការ និងលំដាប់លំដោយនៃអាទិភាពចំណាយទាំងអស់ក្នុងការរៀបចំគម្រោងចំណាយដោយដាក់បញ្ចូលឲ្យបានត្រឹមត្រូវតាមខ្លឹមសារ ចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា។

ដោយឡែកគម្រោងចំណាយរបស់រដ្ឋបាលក្រុង ត្រូវបូកបញ្ចូលនូវគម្រោងចំណាយរបស់រដ្ឋបាលសង្កាត់ទាំងអស់ចំណុះរដ្ឋបាលក្រុង ក្រោយពេលដែលរដ្ឋបាលសង្កាត់ទាំងនោះបានផ្ញើជូននូវគម្រោងថវិកាដែលក្រុមប្រឹក្សារបស់ខ្លួនបានអនុម័តរួច។

**ឃ-២-៣-** នៅថ្នាក់រដ្ឋបាលឃុំ សង្កាត់ មេឃុំ និងចៅសង្កាត់ត្រូវរៀបចំប្រជុំដោយមានការចូលរួមពីស្មៀន និងមន្ត្រីជំនាញ ( បើមាន ) ពិភាក្សាអំពីតម្រូវការ និងលំដាប់លំដោយអាទិភាពនៃចំណាយទាំងអស់ដើម្បីរៀបចំគម្រោងចំណាយដោយដាក់បញ្ចូលឲ្យបានត្រឹមត្រូវតាមខ្លឹមសារ ចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា។

## ង- កាលបរិច្ឆេទនៃការរៀបចំនិងអនុម័តគម្រោងថវិកា

នៅសប្តាហ៍ទី១ នៃខែមិថុនា ឆ្នាំ២០១៣ នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋានត្រូវជូនដំណឹងអំពីថវិកាឧបត្ថម្ភដែលត្រូវផ្ទេរពីថវិកាជាតិទៅថ្នាក់នីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ( មូលនិធិឧបត្ថម្ភកធនរាជធានី ខេត្ត ក្រុង ស្រុកនិងមូលនិធិឃុំ សង្កាត់ ) ដើម្បីរៀបចំគម្រោងថវិការបស់ខ្លួន។

**ង-១-** នៅថ្នាក់រដ្ឋបាលឃុំ មេឃុំនីមួយៗក្រោយពីទទួលបានចំណូលពីការវិភាជន៍មូលនិធិឃុំ សង្កាត់និងលទ្ធភាពចំណូលដែលអាចប្រមូលបាននៅនឹងមូលដ្ឋាន ត្រូវដំណើរការរៀបចំគម្រោងថវិកា និងដាក់ជូនក្រុមប្រឹក្សារបស់ខ្លួនពិនិត្យនិងអនុម័ត យ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៣។

**ង-២-** នៅរដ្ឋបាលថ្នាក់សង្កាត់ ចៅសង្កាត់នីមួយៗក្រោយពីទទួលបានកញ្ចប់ថវិកា( សរុបចំណូល )ពីរដ្ឋបាលរាជធានី និងរដ្ឋបាលក្រុង ត្រូវដំណើរការរៀបចំគម្រោងថវិការួចដាក់ជូនក្រុមប្រឹក្សារបស់ខ្លួនពិនិត្យនិងអនុម័តយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ហើយផ្ញើទៅរដ្ឋបាលរាជធានី និងរដ្ឋបាលក្រុង យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣។

**ង-៣-** នៅថ្នាក់រដ្ឋបាលក្រុង ស្រុក អភិបាលនៃគណៈអភិបាលក្រុង ស្រុក ក្រោយពីបានទទួលចំណូលពីការវិភាជន៍មូលនិធិក្រុង ស្រុក និងលទ្ធភាពចំណូលដែលអាចប្រមូលបាននៅមូលដ្ឋាន ត្រូវដំណើរការរៀបចំគម្រោងថវិកា និងដាក់ជូនក្រុមប្រឹក្សារបស់ខ្លួនពិនិត្យ និងអនុម័តយ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៣។ ចំពោះគម្រោងថវិការបស់រដ្ឋបាលក្រុង ត្រូវបូកបញ្ចូលគម្រោងថវិការបស់រដ្ឋបាលសង្កាត់ទាំងអស់ចំណុះរដ្ឋបាលក្រុង។ អភិបាលនៃគណៈអភិបាលក្រុង ត្រូវបែងចែកនិងជូនដំណឹងអំពីកញ្ចប់ថវិកាដល់រដ្ឋបាលសង្កាត់យ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៣ និងជួយគាំទ្រឲ្យរដ្ឋបាលសង្កាត់រៀបចំគម្រោងថវិកា ដើម្បីដាក់ឆ្លងក្រុមប្រឹក្សារបស់ខ្លួនយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣។

**ខ-៤-** នៅថ្នាក់រដ្ឋបាលខណ្ឌ អភិបាលនៃគណៈអភិបាលខណ្ឌ ក្រោយពីបានទទួលកញ្ចប់ថវិកា(សរុបចំណូល) ពីរដ្ឋបាលរាជធានី ត្រូវដំណើរការរៀបចំគម្រោងថវិកានិងដាក់ជូនក្រុមប្រឹក្សារបស់ខ្លួនពិនិត្យនិងអនុម័ត យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ហើយផ្ញើទៅរដ្ឋបាលរាជធានីយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣។

**ខ-៥-** នៅថ្នាក់រដ្ឋបាលរាជធានី ខេត្ត អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រោយពីបានទទួលកញ្ចប់ថវិកាពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវព្យាករណ៍នូវលទ្ធភាពចំណូលសរុបទាំងអស់ ដើម្បីរៀបចំគម្រោងថវិកានិងដាក់ជូនក្រុមប្រឹក្សារបស់ខ្លួនពិនិត្យនិងអនុម័ត យ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៣។

ចំពោះគម្រោងថវិការបស់រដ្ឋបាលរាជធានីត្រូវបូកបញ្ចូលគម្រោងថវិការបស់រដ្ឋបាលខណ្ឌ និងសង្កាត់ទាំងអស់ចំណុះរដ្ឋបាលរាជធានី។ អភិបាលនៃគណៈអភិបាលរាជធានី ត្រូវបែងចែកនិងជូនដំណឹងអំពីកញ្ចប់ថវិកាដល់រដ្ឋបាលខណ្ឌនិងសង្កាត់យ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៣ និងត្រូវជួយគាំទ្រឲ្យរដ្ឋបាលខណ្ឌ សង្កាត់ រៀបចំគម្រោងថវិកា ដើម្បីដាក់ឆ្លងក្រុមប្រឹក្សារបស់ខ្លួនឲ្យបានយ៉ាងយឺតត្រឹមថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣។

## ច- យន្តការគាំទ្រការរៀបចំគម្រោងថវិកា

**ច-១-** ឆ្នាំ២០១៤ គឺជាឆ្នាំដែលគ្រប់ថ្នាក់រដ្ឋបាលទាំងអស់នៅរដ្ឋបាលថ្នាក់ក្រោមជាតិមានថវិកាផ្ទាល់របស់ខ្លួន ហើយក៏ជាឆ្នាំដែលគ្រប់ថ្នាក់រដ្ឋបាលទាំងអស់នៅរដ្ឋបាលថ្នាក់ក្រោមជាតិ រៀបចំគម្រោងថវិការបស់ខ្លួនទៅតាមទម្រង់និងចំណាត់ថ្នាក់នៃមាតិកាថវិកាឯកភាពមួយ ដើម្បីឆ្លើយតបទៅនឹងខ្លឹមសារនៃការអនុវត្តច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលតម្រូវឲ្យថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងមូលគឺជាកញ្ចប់មួយ និងដាក់បញ្ចូលជាជំពូកមួយនៃសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤។

**ច-២-** នៅក្នុងដំណើរការរៀបចំនិងអនុវត្តថវិកាផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិទៅតាមរចនាសម្ព័ន្ធនៃកំណែទម្រង់រដ្ឋបាលថ្មី ការចាំបាច់បំផុតគឺ តម្រូវឲ្យមានយន្តការគាំទ្រជាប្រចាំដល់ថ្នាក់រដ្ឋបាលទាំងអស់នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសនៅថ្នាក់រដ្ឋបាលឃុំ សង្កាត់។

**ច-៣-** មន្ត្រីអគ្គនាយកដ្ឋានរតនាគារជាតិ នាយកដ្ឋានលទ្ធកម្មសាធារណៈ និងនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចុះជាប្រចាំទៅចូលរួមជាជំនួយការឲ្យក្រុមការងារនៅថ្នាក់រាជធានី ខេត្ត ដើម្បីចល័តជួយគាំទ្រដល់ថ្នាក់ក្រុង ស្រុក ខណ្ឌ និងថ្នាក់ឃុំ សង្កាត់ ដែលជួបបញ្ហាក្នុងការរៀបចំគម្រោងថវិកាឆ្នាំ២០១៤។ ក្នុងករណីចាំបាច់ត្រូវសុំអន្តរាគមន៍ជាបន្ទាន់មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ច-៤-** នៅថ្នាក់រាជធានី ខេត្ត អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវចេញសេចក្តីសម្រេចបង្កើតក្រុមការងារដែលមានប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាប្រធាន ប្រធានរតនាគារជាអនុប្រធាន និងនាយកទីចាត់

ការហិរញ្ញវត្ថុសាលារាជធានី ខេត្តជាសមាជិក ដើម្បីគាំទ្រជាប្រចាំដល់ថ្នាក់រដ្ឋបាលនីមួយៗក្នុងការរៀបចំ និង អនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ក្រុមការងារនេះដោយមានជំនួយការពីមន្ត្រីនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវប្រមូលផ្តុំមេឃុំ និងចៅសង្កាត់នៅថ្នាក់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីពន្យល់ណែនាំអំពីរបៀបរៀប ចំគម្រោងថវិកាឆ្នាំ២០១៤ ទៅតាមទម្រង់និងចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាឯកភាពតែមួយ។

ទទួលបានសារាចរណែនាំនេះ គ្រប់អគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធនៃក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវសហការគ្នាជួយគាំទ្រឲ្យការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០១៤ សម្រេចបានដោយជោគជ័យ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**គាត ឈន់**

**កន្លែងទទួល:**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ

  «ដើម្បីជូនជ្រាប»
- អគ្គនាយកដ្ឋានរតនាគារជាតិ
- គ្រប់សាលារាជធានី ខេត្ត
- គ្រប់សាលាក្រុង ស្រុក ឃុំ សង្កាត់
- គ្រប់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត
- គ្រប់រតនាគាររាជធានី ខេត្ត

  «ដើម្បីមុខការ»
- ឯកសារ